ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ 0243 អបស/ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី 21 ខែ 05 ឆ្នាំ២០០9

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

គោរពជូន

## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន

**កម្មវត្ថុ** : ករណីផ្សព្វផ្សាយពាណិជ្ជកម្មតាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មាន ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។

**យោង** :- ច្បាប់ស្តីពីការគ្រប់គ្រងឱសថ

- ប្រកាសរួមក្រសួងសុខាភិបាល និងក្រសួងព័ត៌មាន លេខ ៧៥/០៦ ពមក្រប-០០៧ អនស/មព ចុះថ្ងៃទី ២១ កុម្ភៈ ឆ្នាំ២០០៦ ស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- លិខិតរបស់ក្រសួងព័ត៌មានលេខ ៤២៧ ពម ចុះថ្ងៃទី ០៧ មេសា ឆ្នាំ២០០៩ ស្តីពីការផ្សាយពាណិជ្ជកម្ម កៅអៀក HINOKOSHIWA និងថ្នាំដុសធ្មេញ Smile On ថ្នាំបណ្តុះសក់ NU-HAIR និងឱសថបូរាណតាមស្ថានីយ៍វិទ្យុ ទូរទស្សន៍ គ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល
- លិខិតលេខ ០៧៩ អេចប៊ីអប៊ីស៊ី ចុះថ្ងៃទី ០៦ មេសា ឆ្នាំ២០០៩ របស់ក្រុមហ៊ុន ហេង បូរ៉ា បណ្ឌិតសេដ្ឋី ស្តីពីសំណើសុំទប់ស្កាត់ការលួចផ្សព្វផ្សាយផលិតផលកៅ អៀក ម៉ាក HINOKOSHIWA និងថ្នាំ ដុសធ្មេញ Smile On.
- សេចក្តីសំរេចលេខ ១១៨៩ អបស/ឱអបស ស្តីពីការអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្ម ថ្នាំដុសធ្មេញ Smile On ចុះថ្ងៃទី ១១ ធ្នូ ឆ្នាំ២០០៨ របស់ក្រុមហ៊ុន ហេង បូរ៉ា
- សេចក្តីសំរេចលេខ ០០៥០ អបស/ឱអបស ស្តីពីការអនុញ្ញាតឱ្យបន្តសុពលភាពផ្សព្វផ្សាយ កៅអៀក ម៉ាក HINOKOSHIWA ចុះថ្ងៃទី ០៣ កុម្ភៈ ឆ្នាំ២០០៥ របស់ក្រុមហ៊ុន ហេង បូរ៉ា ។

សេចក្តីដូចបានជំរាបក្នុងកម្មវត្ថុ និងយោងខាងលើ ជាថ្មី ម្តងទៀតក្រសួងសុខាភិបាលមានកិត្តិយសជំរាបជូនឯកឧត្តម ជួយធ្វើអន្តរាគមន៍ផ្អាកការផ្សព្វផ្សាយពាណិជ្ជកម្មគ្មានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ពីសំណាក់ក្រុមហ៊ុន អាហារ៍ណ នីហារ៍ណ និងគ្រូឱសថបូរាណមួយចំនួនតាមរយៈ សារព័ត៌មាន វិទ្យុ និងទូរទស្សន៍ ដូចមានរាយឈ្មោះខាងក្រោម :

១/. <u>ក្រុមហ៊ុន អាហារ៍ណ នីហារ៍ណ ដែលផ្សព្វផ្សាយ កៅអៀក ម៉ាក HINOKOSHIWA និងថ្នាំដុសធ្មេញ Smile On</u>

ក- ក្រុមហ៊ុន សូ លានគ្រុប ផ្សាយតាមវិទ្យុ :

| | |
|---|---|
| -វិទ្យុ FM 93.5 ( ភ្នំពេញ ) | ពីម៉ោង ៤:00 ដល់ ៥:00 ល្ងាច |
| -វិទ្យុ FM 96 ( ភ្នំពេញ ) | ពីម៉ោង ១០:00 ដល់ ១១:00 ព្រឹក ។  ៤ |

570 ៸៸ ១

ខ- ក្រុមហ៊ុន សាលីន សុផល ផ្សាយតាមវិទ្យុ :

-វិទ្យុ FM 90.5 ( ភ្នំពេញ ) ពីម៉ោង ១១:០០ ដល់ ១២:០០ ថ្ងៃត្រង់

-វិទ្យុ FM 104 ( ភ្នំពេញ ) ពីម៉ោង ៣:០០ ដល់ ៥:០០ ល្ងាច

-វិទ្យុ FM 103.75 ( ខេត្តស្វាយរៀង ) ។

គ-.ក្រុមហ៊ុន Green World ផ្សាយតាមវិទ្យុ :

-វិទ្យុ FM 91 ( ខេត្តបាត់ដំបង ) ម៉ោង ៧:០០ ដល់ ៨:៣០នាទី យប់ ។

២/. គ្រូឱសថបុរាណ ហោលីម :

-ផ្សាយតាមសារព័ត៌មាន មនសិការខ្មែរ រៀងរាល់ថ្ងៃ ( អត្ថបទផ្សព្វផ្សាយជូនភ្ជាប់ )

-ផ្សាយតាមវិទ្យុ FM 93.5 ( ភ្នំពេញ ) ម៉ោង ៥:០០ ព្រឹក និងម៉ោង ៧:០០ យប់ ។

៣/. គ្រូឱសថបុរាណ សួស សារិន ( សញ្ញាអន្តរគុណ សម័យអង្គរ ) :

-ផ្សាយតាមវិទ្យុជាតិ AM 918 ( ភ្នំពេញ ) ។

៤/. គ្រូឱសថបុរាណ សញ្ញា កូនភ្លោះ ( គ្មានបញ្ចេញឈ្មោះ ) :

-ផ្សាយតាមទូរទស្សន៍ ខ្មែរ ប៉ុស្តិ៍លេខ ៩ ។

ទន្ទឹមនឹងនេះក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមដែលបានក្រើនរំលឹកកន្លងមក ដល់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដែលទទួលផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ បុរាណ និងគ្រឿងសំអាង គ្មានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថាឯកឧត្តមនឹងបន្តជួយសហការលុបបំបាត់ភាពអនាធិបយ្យក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម គ្មានការអនុញ្ញាតនេះជាពុំខាន ។

សូមឯកឧត្តមទទួលនូវការរាប់អានអំពីខ្ញុំ ។

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-សាលាក្រុងភ្នំពេញ

-អគ្គនាយកបច្ចេកទេសសុខាភិបាល

-លេខាធិការដ្ឋានគណៈកម្មការអន្តរក្រសួង

លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់

-នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង

-មន្ទីរសុខាភិបាលខេត្ត ស្វាយរៀង និង បាត់ដំបង

"ដើម្បីជ្រាបជាពត៌មាន"

-ឯកសារ-កាលប្បវត្តិ

ម៉ម_ប៊ុនហេង